41.14		ស្បែកសត្វកៅស៊ូ (រួមបញ្ចូលទាំងកៅស៊ូគួបគ្នា) ស្បែកខ្មៅរលោង ស្បែកកិនជាបន្ទះ ស្បែកមានជាតិលោហៈ	**Chamois (including combination chamois) leather; patent leather and patent laminated leather; metallised leather.**						
	4114.10.00	- ស្បែកសត្វកៅស៊ូ (រួមបញ្ចូលទាំងកៅស៊ូគួបគ្នា)	- Chamois (including combination chamois) leather	kg	7	0	10	10	
	4114.20.00	- ស្បែកខ្មៅរលោង ស្បែកកិនជាបន្ទះ ស្បែកមានជាតិលោហៈ	- Patent leather and patent laminated leather; metallised leather	kg	7	0	10	10	
41.15		ស្បែកផ្សំជាមួយស្បែក ឬសរសៃស្បែក ជាបន្ទះ សន្លឹក ឬជាច្រៀក ទោះជាមិនមែនជាមូរ ។ សំណល់ការច្នៃស្បែកផ្សំមិនអាចយកទៅផលិត ជាអ្វីបាន។ ធូលីស្បែក ម្សៅស្បែក	**Composition leather with a basis of leather or leather fibre, in slabs, sheets or strip, whether or not in rolls; parings and other waste of leather or of composition leather, not suitable for the manufacture of leather articles; leather dust, powder and flour.**						
	4115.10.00	- ស្បែកផ្សំជាមួយស្បែក ឬសរសៃស្បែក ជាបន្ទះ សន្លឹក ឬជាច្រៀក ទោះជាមិនមែនជាមូរ	- Composition leather with a basis of leather or leather fibre, In slabs, sheets or strip, whether or not In rolls	kg	7	0	10	10	
	4115.20.00	- សំណល់ការច្នៃស្បែកផ្សំ មិនអាចយកទៅផលិតជាអ្វីបាន ធូលីស្បែក ឬម្សៅស្បែក	- Parings and other waste of leather or of composition leather, not suitable for the manufacture of leather articles; leather dust, powder and flour.	kg	7	0	10	10	

ជំពូកទី ៤២

វត្ថុធ្វើអំពីស្បែក បរិក្ខារធ្វើពីពោមសត្វ បរិក្ខារបំពាក់កែបសេះ បង្ហៀរសេះ គ្រឿងប្រដាប់សំរាប់ការធ្វើដំណើរ កាបូបដៃ និងប្រដាប់ដាក់វត្ថុប្រហាក់ ប្រហែលគ្នា វត្ថុធ្វើពីពោះវៀន (ក្រៅពីវត្ថុធ្វើពីសូត្រដង្កូវនាង)

Chapter 42

Articles of leather; saddlery and harness;travel goods, handbags and similar containers;articles of animal gut (other than silk-worm gut)

កំណត់សំគាល់

Notes

1.- ជំពូកនេះមិនរាប់បញ្ចូល :

This Chapter does not cover :

(a) ខេស វះកាត់ ឬ catgut (គ្មានមេរោគ) និងបណ្តាខេសគ្មានមេរោគប្រហាក់ប្រហែលគ្នា សំរាប់ដេរភ្ជិតក្នុងសល្យកម្ម (ការវះកាត់) ទីតាំងលេខ ៣០.០៦ ។

Sterile surgical catgut or similar sterile suture materials (heading No. 30.06);

(b) សំលៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ (ក្រៅពីស្រោមដៃ) ធ្វើពីស្បែក ឬទ្រនាប់នូវស្បែកមានរោមធម្មជាតិ ឬមិនមែនធម្មជាតិ ព្រមទាំងសំលៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ធ្វើពីស្បែកដែលពាសពីក្រៅពីស្បែកមានរោមធម្មជាតិ ឬមិនមែនធម្មជាតិកាលណាភាគទាំងនោះមិនមែនជាគ្រឿងចោមលំអ ទីតាំងលេខ ៤៣.០៣ ឬ ៤៣.០៤ ។

Articles of apparel or clothing accessories (except gloves), lined with furskin or artificial fur or to which furskin or artificial fur is attached on the outside except as mere trimming (heading No. 43.03 or 43.04);

(c) បរិក្ខារកាត់ដេរជាសំណាញ់នៃទីតាំងលេខ ៥៦.០៨

Made up articles of netting (heading No. 56.08);

(d) បរិក្ខារនៃជំពូកទី ៦៤

Articles of Chapter 64;

(e) ប្រដាប់ពាក់លើក្បាល និងបណ្តាផ្នែកធ្វើសក់នៃជំពូក ៦៥

Headgear or parts thereof of Chapter 65;

Custom

	(f)	ខ្សែតី រំពាត់ស្បែក និងរបស់របរដទៃទៀត នៃទីតាំងលេខ ៦៦.០២	Whips, riding-crops or other articles of heading No. 66.02;
	(g)	គ្រឿងតែងលំអ ក្រវិល ចិញ្ចៀន ខ្សែដៃ ឬគ្រឿងអលង្ការក្លែងដទៃទៀតនៃទីតាំងលេខ ៧១.១៧ ។	Cuff-links, bracelets or other imitation jewellery (heading No. 71.17);
	(h)	គ្រឿងបន្ទាប់បន្សំ និងគ្រឿងតែងលំអរកែបសេះឬបង្ហៀរសេះ (ឧទាហរណ៍ បង្កាំង បង្ហៀរសេះ ឈ្នាន់កែបសេះ ក្រវិល) ដែលដាក់ដាច់ចេញដោយឡែកពីគ្នា (ផ្នែក xv ជាទូទៅ)។	Fittings or trimmings for harness, such as stirrups, bits, horse brasses and buckles, separately presented (generally Section XV);
	(ij)	ខ្សែសំរាប់គ្រឿងភ្លេងស្បែកដាក់ស្គរឬឧបករណ៍ប្រហាក់ប្រហែលគ្នាព្រមទាំងផ្នែកនៃឧបករណ៍ភ្លេងដទៃទៀតនៃទីតាំងលេខ ៩២.០៩ ។	Strings, skins for drums or the like, or other parts of musical instruments (heading No. 92.09);
	(k)	បរិក្ខារនៃជំពូក ៩៤ (ឧទាហរណ៍ សង្ហារឹម គ្រឿងប្រដាប់សំរាប់បំភ្លឺ)។	Articles of Chapter 94 (for example, furniture, lamps and lighting fittings);
	(l)	បរិក្ខារនៃជំពូក ៩៥ (ឧទាហរណ៍ គ្រឿងល្បែង ឧបករណ៍កីឡា) ។	Articles of Chapter 95 (for example, toys, games, sports requisites); or
	(m)	ឡេវ ឡេវគៀប ទំរង់ប្រើប្រាស់ជាឡេវ គុម្ព និងភាគដទៃទៀតនៃឡេវ ឬឡេវគៀបរបស់បញ្ចេញនៃឡេវទីតាំងលេខ ៩៦.០៦ ។	Buttons, press-fasteners, snap-fasteners, press-studs, button moulds or other parts of these articles, button blanks, of heading No. 96.06.
2.-	(A)	ក្រៅពីបទបញ្ញត្តិនៃកំណត់សំគាល់ទី ១ ខាងលើនៃទីតាំងលេខ ៤២.០២ មិនរាប់បញ្ចូល :	In addition to the provisions of Note 1 above, heading No. 42.02 does not cover :
	(a)	កាបូបធ្វើពីសន្លឹកប្លាស្ទិក ទោះបីជាសន្លឹកបោះពុម្ពដោយពុម្ពក៏ដោយ មានដៃយួរ មិនធានាដល់ការប្រើប្រាស់យូរអង្វែងក៏ដោយ ទីតាំងលេខ ៣៩.២៣ ។	Bags made of sheeting of plastics, whether or not printed, with handles, not designed for prolonged use (heading No. 39.23);
	(b)	របស់របរធ្វើពីវត្ថុធាតុដែលក្រង ត្បាញទីតាំងលេខ ៤៦.០២ ។	Articles of plaiting materials (heading No. 46.02).

Departmen

(B)

របស់របរនៃទីតាំងលេខ ៤២.០២ និង ៤២.០៣ ទោះមានផ្នែកផ្សំឡើងពីលោហធាតុមានតំលៃ ឬលោហធាតុស្រោបជាមួយលោហធាតុមានតំលៃ ឬ គុជធម្មតា គុជមានតំលៃពីថ្មមានតំលៃ ឬពាក់កណ្តាលមានតំលៃ (ធម្មជាតិសំយោគ ឬថ្មឡើងវិញ) ក៏ដោយក៏ត្រូវតែចាត់ថ្នាក់ក្នុងទីតាំងនេះដែរ (៤២.០២ និង ៤២.០៣)ហើយទោះជាផ្នែកផ្សំទាំងនោះធ្វើឡើងក្នុងបំណងជួយសំរួលការប្រើប្រាស់ ឬ រំលេច លំអ តិច ឬច្រើនក្តី លើកលែងតែផ្នែកផ្សំឡើងឱ្យប្រែប្រួលដល់ឈ្មោះដើមរបស់ទាំងនោះ ត្រូវចាត់ថ្នាក់ក្នុងជំពូក ៧១។

Articles of headings Nos. 42.02 and 42.03 which have parts of precious metal or metal clad with precious metal, of natural or cultured pearls, of precious or semi-precious stones (natural, synthetic or reconstructed) remain classified in those headings even if such parts constitute more than minor fittings or minor ornamentation, provided that these parts do not give the articles their essential character. If, on the other hand, the parts give the articles their essential character, the articles are to be classified in Chapter 71.

3.- តាមអត្ថន័យនៃទីតាំងលេខ ៤២.០៣ ពាក្យថា "សំលៀកបំពាក់និងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់" អនុវត្តពិសេសទៅលើស្រោមដៃ (រួមមានស្រោមដៃកីឡា និងស្រោមដៃការពារ) លើអៀមបាំងពីមុខកុំឱ្យប្រឡាក់ និងបរិក្ខារពិសេសសំរាប់ការពារដទៃទៀតសំរាប់គ្រប់មុខវិជ្ជាជីវៈ មានខ្សែប្រយុង ខ្សែក្រវ៉ាត់ សំងទ្រុង ខ្សែស្លាយ និងខ្សែយួរដៃ ក៏ប៉ុន្តែលើកលែងតែខ្សែនាឡិកាដៃនៃទីតាំងលេខ ៩១.១៣ ។

For the purposes of heading No. 42.03, the expression "articles of apparel and clothing accessories" applies, inter alia, to gloves (including sports gloves), aprons and other protective clothing, braces, belts, bandoliers and wrist straps, but excluding watch straps (heading No. 91.13).

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp.			Exp.	
					CD	ST	VAT	ET	
42.01	4201.00.00	ប្រដាប់បំពាក់នៃកែបសេះ និងបង្ហៀរសំរាប់គ្រប់សត្វទាំងអស់ (នៅក្នុងនោះរួមមានខ្សែទាញ ខ្សែដឹក គ្រឿងការពារជង្គង់ ខ្សែរឹត កំរាលកែប អាវប៉ង់ឆ្កែសំរាប់ឆ្កែ និងរបស់របរប្រហាក់ប្រហែលគ្នានោះ) ធ្វើពីគ្រប់វត្ថុធាតុគ្រប់ប្រភេទ។	Saddlery and harness for any animal (including traces, leads, knee pads, muzzles, saddle cloths, saddle bags, dog coats and the like), of any material.	kg	35	0	10	0	
42.02		ហិប វ៉ាលី និងហិបតូច (រួមបញ្ចូលទាំងកូនហិបសំរាប់ដាក់គ្រឿងលំអកាយ សំពៀតកាតាបស្រោមដាក់វ៉ែនតា ដាក់កែវយឺត ដាក់ប្រដាប់ប្រដាថតរូប ដាក់ម៉ាស៊ីនថត ដាក់ឧបករណ៍ ភ្លេងឬអាវុធ និងប្រដាប់ដាក់ប្រហាក់ប្រហែលគ្នា ស្បោងធ្វើដំណើរ ឃ្លុកដាក់គ្រឿងលុប លាងកាយ សំពៀត ស្ពាយនៅខ្នង កាបូបដៃ ស្បោង ដាក់គ្រឿង ហូបចុក សំពៀតដាក់ ក្រដាស ស្នាមឃ្លុកដាក់ប្រាក់ ស្រោមផែនទី ប្រអប់ដាក់បារី ឃ្លុកថ្នាំជក់ ស្បោងដាក់ប្រដាប់ប្រដាកីឡា ប្រអប់សំរាប់ដាក់កូនដប ឬគ្រឿងអលង្ការ ប្រអប់ម្សៅ ប្រអប់ដាក់ គ្រឿង មាស ប្រាក់និងប្រដាប់ប្រហាក់ប្រហែលគ្នាធ្វើពីស្បែកធម្មជាតិ ឬស្បែក ផ្សំពីសន្លឹក នៃវត្ថុធាតុ ប្លាស្ទិកពីវត្ថុធាតុវាយនភ័ណ្ឌ ពីសរសៃមានស្ពាន់ធ័រ ឬពាតុង ឬស្រោបទាំងស្រុង ឬផ្នែកសំខាន់ណាមួយដូចគ្នា ។	Trunks, suit-cases, vanity-cases, executive-cases, brief-cases, school satchels, spectacle cases, binocular cases, camera cases, musical instrument cases, gun cases, holsters and similar containers; travelling bags, toilet bags, rucksacks, handbags, shopping-bags, wallets, purses, map cases, cigarette-cases, tobacco-pouches, tool bags, sports bags, bottle cases, jewellery boxes, powder-boxes, cutlery cases and similar containers, of leather or of composition leather, of sheeting of plastics, of textile materials, of vulcanised fibre or of paperboard, or wholly or mainly covered with such materials or with paper.						
		- ហិប វ៉ាលី និងហិបតូច រាប់បញ្ចូលទាំងហិបតូចសំរាប់គ្រឿងបន្ទប់ទឹក ហិបតូចឯកសារ កាបូប កាតាប និងហិបតូចប្រហាក់ប្រហែល :	- Trunks, suit-cases, vanity-cases, executive-cases, brief-cases, school satchels and similar containers:						
	4202.11	- - ដែលមានផ្ទៃខាងក្រៅធ្វើពីស្បែកធម្មជាតិ ធ្វើពីស្បែកផ្សំ ឬធ្វើពីស្បែករលោង :	- - With outer surface of leather, of composition leather or of patent leather						

	4202.11.10	- - - កាតាបសិស្ស	- - - School satchels	u	7	0	10	0	
	4202.11.90	- - - ផ្សេងទៀត	- - - Other	u	35	0	10	0	
	4202.12	- - ដែលមានផ្ទៃខាងក្រៅធ្វើពីប្លាស្ទិក ឬវាយនភ័ណ្ឌ :	- - With outer surface of plastics or of textile materials :						
	4202.12.10	- - - កាតាបសិស្ស	- - - School satchels	u	7	0	10	0	
	4202.12.90	- - - ផ្សេងទៀត	- - - Other	u	35	0	10	0	
	4202.19	- - ផ្សេងទៀត :	- - Other :						
	4202.19.10	- - - ពីឈើ, ដែក, ដែកថែប ឬស័ង្កសី	- - - Of wood, iron, steel or zinc	u	35	0	10	0	
	4202.19.90	- - - ផ្សេងទៀត	- - - Other	u	35	0	10	0	
		- កាបូបដៃដែលគ្មានខ្សែស្ពាយ ឬមានរាប់បញ្ចូលទាំងកាបូបដៃដែលគ្មានដៃយួរ	- Handbags, whether or not with shoulder strap, including those without handle						
	4202.21.00	- - ដែលមានផ្ទៃខាងក្រៅធ្វើពីស្បែកធម្មជាតិ ពីស្បែកផ្សំ ឬស្បែករលោង	- - With outer surface of leather, of composition leather or of patent leather	u	35	0	10	0	
	4202.22.00	- - ដែលមានផ្ទៃខាងក្រៅធ្វើពីប្លាស្ទិក ឬវាយនភ័ណ្ឌ	- - With outer surface of plastic sheeting or of textile materials	u	35	0	10	0	
	4202.29.00	- - ផ្សេងទៀត	- - Other	u	35	0	10	0	
		- វត្ថុប្រភេទដាក់ក្នុងហោប៉ៅ ឬក្នុងកាបូបដៃ :	- Articles of a kind normally carried in the pocket or in the handbag :						
	4202.31.00	- - ដែលមានផ្ទៃខាងក្រៅធ្វើពីស្បែកធម្មជាតិ ពីស្បែកផ្សំ ឬស្បែករលោង	- - With outer surface of leather, of composition leather or of patent leather	kg	35	0	10	0	
	4202.32.00	- - ដែលមានផ្ទៃខាងក្រៅធ្វើពីប្លាស្ទិក ឬវាយនភ័ណ្ឌ	- - With outer surface of plastic sheeting or of textile materials	kg	35	0	10	0	
	4202.39.00	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
		- ផ្សេងទៀត :	- Other :						
	4202.91	- - ដែលមានផ្ទៃខាងក្រៅធ្វើពីស្បែកធម្មជាតិ ពីស្បែកផ្សំ ឬស្បែករលោង	- - With outer surface of leather, of composition leather or of patent leather						
	4202.91.10	- - - កាតាបកីឡា	- - - Sport bags	kg	35	0	10	0	
	4202.91.90	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	
	4202.92	- - ដែលមានផ្ទៃខាងក្រៅធ្វើពីប្លាស្ទិក ឬវាយនភ័ណ្ឌ	- - With outer surface of plastic sheeting or of textile materials						

	4202.92.10	- - - កាតាបប៊ូលលីង	- - - Bowling bags	kg	35	0	10	0	
	4202.92.90	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	
	4202.99	- - ផ្សេងទៀត :	- - Other :						
	4202.99.10	- - - ពីស្ពាន់	- - - Of copper	kg	35	0	10	0	
	4202.99.90	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	
42.03		សំលៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ធ្វើពីស្បែកធម្មជាតិ ឬ ស្បែកផ្សំ។	Articles of apparel and clothing accessories, of leather or of composition leather.						
	4203.10.00	- សំលៀកបំពាក់	- Articles of apparel	kg	35	0	10	0	
		- ស្រោមដៃ និង ស្រោមដៃឥតម្រាម :	- Gloves, mittens and mitts :						
	4203.21.00	- - ផលិតសំរាប់តែកីឡា	- - Specially designed for use in sports	kg	35	0	10	0	
	4203.29	- - ស្រោមដៃមានម្រាម និងស្រោមដៃឥតម្រាមផ្សេងទៀត	- - Other gloves , mittens and mitts						
	4203.29.10	- - - ស្រោមដៃពាក់សម្រាប់ការពារពេលធ្វើការ	- - - Protective work gloves	kg	35	0	10	0	
	4203.29.90	- - - ផ្សេងទៀត	- - - Other	kg	35	0	10	0	
	4203.30.00	- ខ្សែក្រវ៉ាត់ និងខ្សែក្រវ៉ាត់សំរាប់ខាងហាងមានហោប៉ៅតូចដាក់គ្រាប់	- Belts and bandoliers	kg	35	0	10	0	
	4203.40.00	- គ្រឿងបន្ទាប់បន្សំសំរាប់សំលៀកបំពាក់ផ្សេងទៀត	- Other clothing accessories	kg	35	0	10	0	
42.04		វត្ថុធ្វើពីស្បែកសម្លាប់ ឬធ្វើពីស្បែកសម្លាប់ ឬប្រភេទប្រើក្នុងម៉ាស៊ីន ឧបករណ៍មេកានិច ឬការប្រើប្រាស់ខាងបច្ចេកទេសផ្សេងទៀត	Articles of leather or of composition leather of a kind used in machinery or mechanical appliances or for other technical uses.						
42.05		វត្ថុផ្សេងទៀតធ្វើពីស្បែក ឬពីស្បែកផ្សំ	Other articles of leather or of composition leather.						
	4205.00.10	- ខ្សែស្បែកជើង កំរាល	- Boot laces; mats	kg	35	0	10	0	
	4205.00.20	- ខ្សែក្រវ៉ាត់សុវត្ថិភាពឧស្សាហកម្ម ឬខ្សែបំពាក់	- Industrial safety belts and harnesses	kg	7	0	10	0	
	4205.00.30	- ខ្សែ ឬសរសៃស្បែកសម្រាប់គ្រឿងអលង្ការ ឬបចង្កេះ	- Leather strings or cords for jewelry or for personal adornment	kg	35	0	10	0	

	4205.00.40	- វត្ថុផងទៃដែលប្រើក្នុងម៉ាស៊ីន ឬ សំភារៈមេកានិក ឬសំភារៈបច្ចេកទេសផ្សេងទៀត	- Other articles of a kind used in machinery or mechanical appliances or for other technical uses	kg	35	0	10	0	
	4205.00.90	- ផ្សេងទៀត	- Other	kg	35	0	10	0	
42.06	4206.00.00	វត្ថុធ្វើពីពោះវៀនសត្វ ពីស្បែកស្តើង ពីប្លោកនោម ឬពីសរសៃពួរ	Articles of gut (other than silk-worm gut), of goldbeater's skin, of bladders or of tendons.	kg	7	0	10	0	

ជំពូកទី ៤៣

Chapter 43

ស្បែកជាប់រោម ស្បែកសិប្បនិម្មិត និងផលិតផលរបស់វា

Furskins and artificial fur; manufactures thereof

កំណត់សំគាល់

Notes

1.- ក្រៅពីស្បែកជាប់រោមមិនទាន់ច្នៃនៃទីតាំងលេខ ៤៣.០១ ពាក្យ (ស្បែកជាប់រោម) នៅក្នុងនេះគឺនិយាយពីស្បែកសំលាប់ហើយឬរៀបចំហើយមិនទាន់ដុះរោមចេញរបស់គ្រប់សត្វទាំងអស់។

Throughout the Nomenclature references to "furskins", other than to raw furskins of heading No. 43.01, apply to hides or skins of all animals which have been tanned or dressed with the hair or wool on.

2.- ជំពូកនេះមិនរាប់បញ្ចូល :

This Chapter does not cover :

(a) ស្បែកស្រស់ និងផ្នែកនៃស្បែកស្រស់នៃសត្វស្លាបមានជាប់ស្លាបឬរោមទីតាំងលេខ ០៥.០៥ ឬ ៦៧.០១

Birdskins or parts of birdskins, with their feathers or down (heading No. 05.05 or 67.01);

(b) ស្បែកមិនទាន់ច្នៃមិនដុះរោមនៃប្រភេទស្បែកដែលមានកំណត់សំគាល់ ១(គ) នៃជំពូកទី ៤១ បានចាត់ទៅជំពូកចុងក្រោយនេះ

Raw hides or skins, with the hair or wool on, of Chapter 41 (see Note 1 (c) to that Chapter);

(c) បណ្តាស្រោមដៃដែលមានជាប់រោមធម្មជាតិ ឬសិប្បនិម្មិតផង និងនៃស្បែកសម្លាប់ផងទីតាំងលេខ ៤២.០៣

Gloves consisting of leather and furskin or of leather and artificial fur (heading No. 42.03);

(d) របស់នៃជំពូកទី ៦៤

Articles of Chapter 64;

(e) បណ្តាប្រដាប់គែងលំអ និងពាក់ក្បាល និងភាគខ្លះនៃជំពូកទី ៦៥

Headgear or parts thereof of Chapter 65; or

(f) របស់នៃជំពូកទី ៩៥ (ឧទា. ប្រដាប់ក្មេងលេង គ្រឿងលេង ប្រដាប់ប្រដាកីឡា)

Articles of Chapter 95 (for example, toys, games, sports requisites).

3.- ទីតាំងលេខ ៤៣.០៣ រាប់បញ្ចូលស្បែកជាប់រោម និងភាគផ្សំនីមួយៗ នៃស្បែកមានរោមសត្វ និងភាគរបស់វាដេរជាសំលៀកបំពាក់នៃបណ្តាផ្នែក ឬគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ ឬជារបស់ដទៃទៀត ។

Heading No. 43.03 includes furskins and parts thereof, assembled with the addition of other materials, and furskins and parts thereof, sewn together in the form of garments or parts or accessories of garments or in the form of other articles.

4.- ចូលទៅទីតាំងលេខ ៤៣.០៣ ឬ ៤៣.០៤ យោលតាមករណីសំលៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់គ្រប់ប្រភេទ (ក្រៅពីសំលៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ដាត់ចេញពីជំពូកនេះ តាមរយៈកំណត់សំគាល់ទី ២) មានទ្រនាប់ស្បែកជាប់រោមធម្មជាតិ ឬមិនធម្មជាតិព្រមទាំងសំលៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់ដែលផ្នែកក្នុងមានស្បែកជាប់រោមធម្មជាតិ ឬមិនធម្មជាតិកាលបើភាគទាំងនោះមិនមែនជាគ្រឿងចោមលំអ ។

Articles of apparel and clothing accessories (except those excluded by Note 2) lined with furskin or artificial fur or to which furskin or artificial fur is attached on the outside except as mere trimming are to be classified in heading No. 43.03 or 43.04 as the case may be.

5.- នៅក្នុងនាមវល្លីនេះគេចាត់ទុកថា "ស្បែកមានរោមមិនធម្មជាតិ" មានន័យថាស្បែក ក្លែងដែលមានរោមធ្វើពីខ្សែរ ពីរោម ឬពីសរសៃដទៃៗទៀតដែលបានទទួលដោយ ការបិទ ឬដេរនៅលើស្បែក លើក្រណាត់ ឬលើវត្ថុធាតុផ្សេងទៀត លើកលែងតែស្បែក ក្លែងជាប់រោមធ្វើឡើងដោយការតម្បាញ ឬការចាក់ (ទីតាំងលេខ ៥៨.០១ ឬ ៦០.០១)

Throughout the Nomenclature the expression "artificial fur" means any imitation of furskin consisting of wool, hair or other fibres gummed or sewn on to leather, woven fabric or other materials, but does not include imitation furskins obtained by weaving or knitting (generally, heading No. 58.01 or 60.01).

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods	Unit	Duty and Tax (%) Imp. CD	Imp. ST	Imp. VAT	Exp. ET	Reference
43.01		ស្បែកមានរោមមិនទាន់ច្នៃ (រាប់បញ្ចូលទាំងក្បាល កន្ទុយ ជើង និងផ្នែកផ្សេងទៀត ដែលអាចប្រើបានក្នុងជំនួញ) ស្បែកមានរោមក្រៅពីស្បែក មិនទាន់ច្នៃនៃទីតាំងលេខ ៤១.០១ ៤១.០២ ឬ ៤១.០៣ ។	**Raw furskins (including heads, tails, paws and other pieces or cuttings, suitable for furriers' use), other than raw hides and skins of heading No. 41.01, 41.02 or 41.03.**						
	4301.10.00	- នៃសំពោចទាំងមូល មានឬគ្មានក្បាល កន្ទុយ ឬ ជើង	- Of mink, whole, with or without head, tail or paws	kg	15	0	10	0	
	4301.30.00	- នៃកូនចៀមហៅថាអាស្ត្រាខាន ប្រ៊តថែ៍ ការ៉ាគុល ពែស៊ីយ៉ានៃ ឬ ប្រហាក់ប្រហែលនៃកូនចៀមឥណ្ឌា ចិន ម៉ុងហ្គោលី ឬទីបេទាំងមូល មានឬគ្មានក្បាល កន្ទុយ ឬជើង ។	- Of lamb, the following: Astrakhan, Broadtail , Caracul, Persian and similar lamb , Indian, Chinese, Mongolian or Tibetan lamb, whole, with or without head, tail or paws	kg	15	0	10	0	
	4301.60.00	- នៃកញ្ជ្រោងទាំងមូល មានឬគ្មានក្បាល កន្ទុយ ឬជើង	- Of fox, whole, with or without head, tail or paws	kg	15	0	10	0	
	4301.80.00	- ស្បែកមានរោមផ្សេងទៀតទាំងមូល មានឬគ្មានក្បាល កន្ទុយ ឬជើង	- Other furskins, whole, with or without head, tail or paws	kg	15	0	10	0	
	4301.90.00	- ក្បាល កន្ទុយ ជើងនិងផ្នែកផ្សេងទៀតអាចប្រើបានក្នុងជំនួញស្បែកមានរោម	- Heads, tails, paws and other pieces or cuttings, suitable for furriers' use	kg	15	0	10	0	
43.02		ស្បែកមានរោមសម្លាប់ ឬជ្រលក់ហើយរាប់បញ្ចូលទាំងក្បាល កន្ទុយ ជើង និងចំណែកផ្សេងទៀតមិនទាន់ផ្គុំ ឬផ្គុំហើយ (គ្មានថែមវត្ថុធាតុផ្សេងទៀត) ក្រៅពីស្បែកនៃទីតាំងលេខ ៤៣.០៣	**Tanned or dressed furskins (including heads, tails, paws and other pieces or cuttings), unassembled, or assembled (without the addition of other materials) other than those of heading No. 43.03.**						
		- ស្បែកទាំងមូល មានឬគ្មានក្បាល កន្ទុយ ឬជើងមិនទាន់ផ្គុំ :	- Whole skins, with or without head, tail or paws, not assembled :						
	4302.11.00	- - នៃសំពោច	- - Of mink	kg	35	0	10	0	
	4302.19.00	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
	4302.20.00	- ក្បាល កន្ទុយ ជើង និងផ្នែកផ្សេងទៀតមិនទាន់ផ្គុំ	- Heads,tails, paws and other pieces or cuttings, not assembled	kg	35	0	10	0	
	4302.30.00	- ស្បែកទាំងមូល និងផ្នែករបស់វាផ្គុំហើយ	- Whole skins and pieces or cutting thereof ,assembled	kg	35	0	10	0	

43.03		សំលៀកបំពាក់ គ្រឿងបន្ទាប់បន្សំរបស់វា និងវត្ថុធ្វើពីស្បែកមានរោមផ្សេងទៀត	**Articles of apparel, clothing accessories and other articles of furskin.**						
	4303 10.00	- សំលៀកបំពាក់ និង គ្រឿងបន្ទាប់បន្សំ នៃសំលៀកបំពាក់	- Articles of apparel and clothing accessories	kg	35	0	10	0	
	4303.90	- ផ្សេងទៀត :	- Other :						
	4303.90.20	- - សំភារៈប្រើសម្រាប់គោលបំណងឧស្សាហកម្ម	- - Article for industrial purposes	kg	35	0	10	0	
	4303.90.90	- - ផ្សេងទៀត	- - Other	kg	35	0	10	0	
43.04		រោមសិប្បនិម្មិត និងវត្ថុធ្វើពីរោមសិប្បនិម្មិត	**Artificial fur and articles thereof.**						
	4304.00.10	- រោមសិប្បនិម្មិត	- artificial fur	kg	35	0	10	0	
	4304.00.20	- សំភារៈប្រើសម្រាប់គោលបំណងឧស្សាហកម្ម	- Article for industrial purposes	kg	35	0	10	0	
		- ផ្សេងទៀត :	- Other :						
	4304.00.91	- កាតាបកីឡា	- - Sport bags	kg	35	0	10	0	
	4304.00.99	- - ផ្សេងទៀត	- - Other	kg	35	0	10	0	

ផ្នែកទី IX

Section IX

ឈើ និងវត្ថុធ្វើពីឈើ ធ្យូងឈើ ឆ្នុកក្បាន និងស្នាដៃពីឆ្នុកក្បាន វត្ថុដែលត្បាញពីរុក្ខជាតិ

WOOD AND ARTICLES OF WOOD; WOOD CHARCOAL; CORK AND ARTICLES OF CORK; MANUFACTURES OF STRAW, OF ESPARTO OR OF OTHER PLAITING MATERIALS; BASKETWARE AND WICKERWORK

ជំពូកទី ៤៤

ឈើ ធ្យូងឈើ និងវត្ថុធាតុធ្វើពីឈើ

Chapter 44

Wood and articles of wood; wood charcoal

កំណត់សំគាល់

Notes

1.-		ជំពូកនេះមិនរាប់បញ្ចូល :	This Chapter does not cover :
	(a)	ពពួកចំណាំងឈើ កំទេចឈើ ចំរៀកឈើតូចៗឈើកិនជាកំទេច ជាម្សៅ ប្រភេទឈើដែលប្រើប្រាស់ពិសេសសំរាប់គ្រឿងក្រអូប សំរាប់វេជ្ជសាស្ត្រ ឬក៏សំរាប់សំលាប់សត្វល្អិត ចាក់ស៊ីត ឬពពួកមានលំនាំដូចគ្នា (ទីតាំងលេខ ១២.១១) ។	Wood, in chips, in shavings, crushed, ground or powdered, of a kind used primarily in perfumery, in pharmacy, or for insecticidal, fungicidal or similar purposes (heading No. 12.11);
	(b)	ពពួកឫស្សី និងវត្ថុធាតុផ្សេងទៀតពីឈើប្រភេទប្រើសំរាប់ក្រង ស្ថិតក្នុងស្ថានភាពដើម ចំរៀក ឬទាំងមូល អាចច្រៀក អារ ឬកាត់ ក្នុងទីតាំងលេខ ១៤.០១	Bamboos or other materials of a woody nature of a kind used primarily for plaiting, in the rough, whether or not split, sawn lengthwise or cut to length (heading No. 14.01);
	(c)	ពពួកឈើ និងចំណាំងឈើ កំទេចឈើ ឈើកិនជាកំទេចម្សៅ ពពួករុក្ខផល ប្រើប្រាស់ពិសេសសំរាប់ផ្តល់ពណ៌ ឬការសំលាប់ស្បែកទីតាំងលេខ ១៤.០៤ ។	Wood, in chips, in shavings, ground or powdered, of a kind used primarily in dyeing or in tanning (heading No. 14.04);
	(d)	ពពួកធ្យូងសកម្មទីតាំងលេខ ៣៨.០២	Activated charcoal (heading No. 38.02);
	(e)	បណ្តារបស់នៃទីតាំងលេខ ៤២.០២	Articles of heading No. 42.02;
	(f)	វត្ថុនៃជំពូក ៤៦	Goods of Chapter 46;
	(g)	ពពួកស្បែកជើង និងផ្នែករបស់វាជំពូក ៦៤	Footwear or parts thereof of Chapter 64;
	(h)	របស់នៃក្នុងជំពូក ៦៦ ឧទាហរណ៍ (ឆ័ត្រ ឈើច្រត់ និងភាគរបស់វា) ។	Goods of Chapter 66 (for example, umbrellas and walking-sticks and parts thereof);
	(ij)	វត្ថុក្នុងទីតាំងលេខ ៦៨.០៨	Goods of heading No. 68.08;
	(k)	គ្រឿងអលង្ការ ហ្គេងតែស៊ីក្នុងទីតាំងលេខ ៧១.១៧	Imitation jewellery of heading No. 71.17;
	(l)	របស់នៃផ្នែក XVI ឬផ្នែក XVII ឧទាហរណ៍ (គ្រឿងមេកានិក ប្រអប់ដែកគ្រោម បន្ទប់សំរាប់ម៉ាស៊ីន ឧបករណ៍ គ្រឿងធ្វើប្រកាប់នថ្លើល ។ល។) ។	Goods of Section XVI or Section XVII (for example, machine parts, cases, covers, cabinets for machines and apparatus and wheelwrights' wares);

(m) វត្ថុក្នុងផ្នែក XVIII សំបកគុងនាឡិកា និងឧបករណ៍ភ្លេង និងភាគរបស់វា ។

Goods of Section XVIII (for example, clock cases and musical instruments and parts thereof);

(n) ភាគនៃគ្រឿងសព្វាវុធទីតាំងលេខ ៩៣.០៥

Parts of firearms (heading No. 93.05);

(o) វត្ថុក្នុងជំពូក ៩៤ (ឧទា.គ្រឿងសង្ហារឹម ឧបករណ៍បំភ្លឺ សំណង់ដែលគ្រោងទុកជាមុន)

Articles of Chapter 94 (for example, furniture, lamps and lighting fittings, prefabricated buildings);

(p) វត្ថុនៃជំពូក ៩៥ (ឧទាហរណ៍ ប្រដាប់ក្មេងលេង ល្បែង ឧបករណ៍កីឡា)

Articles of Chapter 95 (for example, toys, games, sports requisites);

(q) វត្ថុនៃជំពូក ៩៦ ឧទាហរណ៍ ខ្សៀ បណ្តាផ្នែករបស់ដងខ្សៀ ឡេវ និងខ្មៅដៃ (លើកលែងតួ ក្រប ដៃ ឬដងឈើសំរាប់វត្ថុនៃទីតាំងលេខ ៩៦.០៣ ។

Articles of Chapter 96 (for example, smoking pipes and parts thereof, buttons, pencils) excluding bodies and handles, of wood, for articles of heading No. 96.03; or

(r) វត្ថុនៃជំពូក ៩៧ (ឧទាហរណ៍ វត្ថុសិល្បៈ)

Articles of Chapter 97 (for example, works of art).

2.- តាមអត្ថន័យជំពូកនេះពាក្យ (ឈើ Densifié) គឺឈើដុំ ឬផ្ទាំងដោយសន្លឹកស្តើងៗ ទទួលប្រព្រឹត្តិកម្មគីមី ឬរូបវិទ្យាចំពោះឈើផ្គុំដោយសន្លឹកស្តើងៗ ប្រព្រឹត្តិកម្មនេះត្រូវ ជំរុញឱ្យខ្លាំងចាំបាច់ដើម្បីធានាភាពស្អិត (ដើម្បីឱ្យជាប់កើនឡើងនូវដង់ស៊ីតេឬភាពរឹង ព្រមទាំងភាពជាប់តទល់និងកំលាំងមេកានិក គីមី ឬអគ្គិសនី។

In this Chapter, the expression "densified wood" means wood which has been subjected to chemical or physical treatment (being, in the case of layers bonded together, treatment in excess of that needed to ensure a good bond), and which has thereby acquired increased density or hardness together with improved mechanical strength or resistance to chemical or electrical agencies.

3.- ក្នុងការអនុវត្តទីតាំងលេខ ៤៤.១៤ ទៅ ៤៤.២១ វត្ថុជាបន្ទះ ឬប្រហាក់ប្រហែលនៃបន្ទះ ជាសរសៃ ជាឈើសាច់ប្រាញ់ៗ ឬឈើសាច់ណែនដោយសម្ពាធមានលំនាំដូចជា វត្ថុដូចគ្នាធ្វើអំពីឈើ ។

Headings Nos. 44.14 to 44.21 apply to articles of the respective descriptions of particle board or similar board, fibreboard, laminated wood or densified wood as they apply to such articles of wood.

4.- ផលិតផលនៃទីតាំងលេខ ៤៤.១០ ៤៤.១១ ឬ ៤៤.១២ អាចធ្វើឱ្យមានរាងជាវត្ថុដូចគ្នាធ្វើពីឈើនៃលេខ ៤៤.០៩ រាងកោង រាងរលកមានរន្ធ ឬមានរាងផ្សេងៗទៀតក្រៅ ពីរាងការេ ឬបួនជ្រុងទ្រវែងឬក៏ធ្វើជាវត្ថុផ្សេងៗទៀតតែកុំឱ្យវត្ថុនេះ មានលក្ខណៈដូចទៅនឹងបណ្តាវត្ថុដែលមានលក្ខណៈចែងនៅក្នុង ទីតាំងផ្សេងៗ ។

Products of heading No. 44.10, 44.11 or 44.12 may be worked to form the shapes provided for in respect of the goods of heading No. 44.09, curved, corrugated, perforated, cut or formed to shapes other than square or rectangular or submitted to any other operation provided it does not give them the character of articles of other headings.

5.- ទីតាំងលេខ ៤៤.១៧ មិនរាប់បញ្ចូលឧបករណ៍ដែលមានផ្លែ មានមុខឬផ្ទៃឬផ្នែកផ្សេង ៗទៀត ដែលត្រូវការប្រើត្រូវបានសាងដោយរូបធាតុប្រើការ ឬភាគប្រើការខ្លះបានត្រូវធ្វើដោយ វត្ថុធាតុចែងក្នុងកំណត់សំគាល់ទី ១ នៃជំពូក ៨២។

Heading No. 44.17 does not apply to tools in which the blade, working edge, working surface or other working part is formed by any of the materials specified in Note 1 to Chapter 82.

6.- តាមកម្មវត្ថុនៃកំណត់សំគាល់ទី១ ខាងលើនិងលើកលែងតែមានចែងនៅទីណាផ្សេងពីនេះពាក្យ "ឈើ " ក្នុងទីតាំងជំពូកនេះអនុវត្តចំពោះឫស្សី និងវត្ថុផ្សេងទៀតដែលមានប្រភពពីឈើ ។

Subject to Note 1 above and except where the context otherwise requires, any reference to "wood" in a heading of this Chapter applies also to bamboos and other materials of a woody nature.

កំណត់សំគាល់ទីតាំងរង :

Subheading Note.

1.- តាមអត្ថន័យនៃទីតាំងរងលេខ ៤៤០៣.៤១ ដល់ ៤៤០៣.៤៩, ៤៤០៧.២៤ ដល់ ៤៤០៧.២៩, ៤៤០៨.៣១ ដល់ ៤៤០៨.៣៩ និង ៤៤១២.១៣ ដល់ ៤៤១២.៩៩ ពាក្យ "ឈើត្រូពិច" សំដៅចំពោះប្រភេទ ឈើទាំងឡាយដូចខាងក្រោមនេះ

For the purposes of subheadings Nos. 4403.41 to 4403.49, 4407.24 to 4407.29, 4408.31 to 4408.39 and 4412.13 to 4412.99, the expression "tropical wood" means one of the following types of wood :

អង្កាញ់ អង្កត់ខ្មៅ របង ឈើខ្មៅ ជើងចាប ច្រេះ ហៃសាញ់ ឬផែសាន ហ្វូនជា ឬម្រះព្រៅភ្នំ ក្រញូង គ្រើស នាងនួន ឬល្បៀង តាត្រាវ ធ្នង់ ក្រយឹង បេលីយ បុសនាគ ម្លូងចែម ស្គង់ កែស គគីរម៉ែក គគីរម្សៅ គគីរថ្ម ក្រកោះ ក្រឡាញ់ មៃសាក់ ផ្ចិត ផ្កាយព្រឹក ពពេល រាំងភ្នំ សំពាំ សង្កត់ត្នោត ស្ពី ស្នៃ សុក្រំ ស្រឡៅ ក្រសេក ទ្រាស អាទិត្យ ឬទាងផ្ទែង ឆាំឆា ល្បើក ឈើទាល ព្រម៉ាស់ ខ្លុង ខ្នុរ ខ្ទាង គគីរឡាច់ គគីរភ្នង ភ្លៀក សុក្រំ ស្រល់ស្រួលក្រហម ត្បែង ទទឹងព្រៃ ក្រាច ត្រឡាត់ បេងខ្មៅ ច័ន្ទក្រឹស្នា ក្តុល គោងកាង ផុង ព្រីង ស្មារក្របី ស្នាច់ ត្នូត ស្វាយព្រៃ ឆ្លក ។

Abura, Acajou d'Afrique, Afrormosia, Ako, Alan, Andiroba, Aningré, Avodiré, Azobé, Balau, Balsa, Bossé clair, Bossé foncé, Cativo, Cedro, Dabema, Dark Red Meranti, Dibétou, Doussié, Framiré, Freijo, Fromager, Fuma, Geronggang, Ilomba, Imbuia, Ipé, Iroko, Jaboty, Jelutong, Jequitiba, Jongkong, Kapur, Kempas, Keruing, Kosipo, Kotibé, Koto, Light Red Meranti, Limba, Louro, Maçaranduba, Mahogany, Makoré, Mansonia, Mengkulang, Meranti Bakau, Merawan, Merbau, Merpauh, Mersawa, Moabi, Niangon, Nyatoh, Obeche, Okoumé, Onzabili, Orey, Ovengkol, Ozigo, Padauk, Paldao, Palissandre de Guatemala, Palissandre de Para, Palissandre de Rio, Palissandre de Rose, Pau Marfim, Pulai, Punah, Ramin, Sapelli, Saqui-Saqui, Sepetir, Sipo, Sucupira, Suren, Teak, Tiama, Tola, Virola, White Lauan, White Meranti, White Seraya, Yellow Meranti.

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods	Unit	Duty and Tax (%)				Reference
					Imp.			Exp.	
					CD	ST	VAT	ET	
44.01		ឈើ ឧសមូល អង្កត់ មែកតូចៗ ឬមានលំនាំដូចគ្នាឈើជាកំទេចតូចៗ អាចម៍រណារ កាក សំណល់ និងកំទេចឈើទោះជាប្រមូលផ្តុំជាអង្កត់ជាកំទេចឬងក្រោមទម្រង់ប្រហាក់ប្រហែល។	**Fuel wood, in logs, in billets, in twigs, in faggots or in similar forms; wood in chips or particles; sawdust and wood waste and scrap, whether or not agglomerated in logs, briquettes, pellets or similar forms.**						
	4401.10.00	- ឧសមូល អង្កត់ មែកតូចៗឧសជាបាច់ឬក្នុង ទម្រង់ប្រហាក់ប្រហែល	- Fuel wood, in logs, in billets, in twigs, in faggots or in similar forms	kg	7	0	10	10	
		- ឈើបន្ទះ ឬជាកំទេច :	- Wood in chips or particles :						
	4401.21.00	- - ប្រភេទកូនីហ្វែ	- - Coniferous	kg	7	0	10	10	
	4401.22.00	- - ប្រភេទមិនមែនកូនីហ្វែ	- - Non-Coniferous	kg	7	0	10	10	
	4401.30.00	- អាចម៍រណារ កំទេចឈើតូច ឬមិនតូចផ្តុំជាអង្កត់ ដុំក្រុង ដុំមូល ឬជាទម្រង់ប្រហាក់ប្រហែល	- Sawdust and other wood waste and scrap, whether or not agglomerated in logs, briquettes, pellets or similar forms	kg	7	0	10	10	
44.02		ធ្យូងឈើ (រាប់បញ្ចូលធ្យូង លលាដ៍ឬសំបក) ទោះជាពូតឬមិនទាន់ពូតផ្តុំ	**Wood charcoal (including shell and nut charcoal), whether or not agglomerated.**						

	4402.10.00	- ពីឫស្សី	- Of bamboo	kg	7	0	10	10	
	4402.90.00	- ផ្សេងទៀត	- Other	kg	7	0	10	10	
44.03		ឈើមិនទាន់ច្នៃទោះជាយក ឬមិនទាន់យកសំបកចេញ យកសែកចេញ ឬឈើឡាំងរួចក៏ដោយ ។	**Wood in the rough, whether or not stripped of bark or sapwood, or roughly squared.**						
	4403.10	- បានលាបថ្នាំ លាបក្រេអូសូល ឬវត្ថុធាតុរក្សាទុកដទៃទៀត	- Treated with paint, stains, creosote or other preservatives						
	4403.10.10	- - ឈើអារជាគ្រឿង	- - Baulks	m^3	7	0	10	10	
	4403.10.90	- - ផ្សេងទៀត	- - Other	m^3	7	0	10	10	
	4403.20	- ផ្សេងទៀត កូនីហ្វែរ	- Other, coniferous						
	4403.20.10	- - ឈើអារ ឬក្តារបន្ទះស្តើង	- - Baulks, sawlogs and veneer logs	m^3	7	0	10	10	
	4403.20.90	- - ផ្សេងទៀត	- - Other	m^3	7	0	10	10	
		- ប្រភេទឈើត្រូពិចផ្សេងទៀត ដូចមានចែងនៅក្នុងទីតាំងរងរបស់កំណត់សំគាល់ទី ១ នៃជំពូកនេះ :	- Other, of tropical wood specified in Subheading Note 1 to this Chapter :						
	4403.41	- - ឈើ Dark Red Meranti , Light Red Meranti and Meranti Bakau	- - Dark Red Meranti, Light Red Meranti and Meranti Bakau						
	4403.41.10	- - - ឈើអារ ឬក្តារបន្ទះស្តើង	- - - Baulks, sawlogs and veneer logs	m^3	7	0	10	10	
	4403.41.90	- - - ផ្សេងទៀត	- - - Other	m^3	7	0	10	10	
	4403.49	- - ផ្សេងទៀត :	- - Other :						
	4403.49.10	- - - ឈើអារ ឬក្តារបន្ទះស្តើង	- - - Baulks, sawlogs and veneer logs	m^3	7	0	10	10	
	4403.49.90	- - - ផ្សេងទៀត	- - - Other	m^3	7	0	10	10	
		- ផ្សេងទៀត	- Other						
	4403.91	- - នៃឈើសែន (Quercus Spp)	- - Of oak (Quercus spp.)						
	4403.91.10	- - - ឈើសម្រាប់ធ្វើក្រដាស	- - - Pulpwood	m^3	7	0	10	10	
	4403.91.90	- - - ផ្សេងទៀត	- - - Other	m^3	7	0	10	10	

	4403.92	- - នៃឈើអែត្រ(Fagus Spp.)	- - Of beech (Fagus spp.)						
	4403.92.10	- - - ឈើសម្រាប់ធ្វើក្រដាស	- - - Pulpwood	m^3	7	0	10	10	
	4403.92.90	- - - ផ្សេងទៀត	- - - Other	m^3	7	0	10	10	
	4403.99	- - ផ្សេងទៀត :	- - Other :						
	4403.99.10	- - - ឈើសម្រាប់ធ្វើក្រដាស	- - - Pulpwood	m^3	7	0	10	10	
	4403.99.90	- - - ផ្សេងទៀត	- - - Other	m^3	7	0	10	10	
44.04		ឈើក្តារ ផន្ទះ បង្គោល ស្រួចចុង មិនអារតាមបណ្តោយ ឈើគ្រាន់តែឡាំងអោយមូល ប៉ុន្តែមិនទាន់ក្តុតអោយកោង ឬច្នៃផ្សេងពីនេះសំរាប់ដំបង ដំត្រ ដងឧបករណ៍ សៀត បន្ទះស្តើង រ៉ូយបដ និងឈើប្រហាក់ប្រហែល	**Hoopwood; split poles; piles, pickets and stakes of wood, pointed but not sawn lengthwise; wooden sticks, roughly trimmed but not turned, bent or otherwise worked, suitable for the manufacture of walking-sticks, umbrellas, tool handles or the like; chipwood and the like.**						
	4404.10.00	- នៃកូនីហ្វែរ	- Coniferous	kg	7	0	10	10	
	4404.20.00	- ក្រៅពីនៃកូនីហ្វែរ	- Non-Coniferous	kg	7	0	10	10	
44.05	4405.00.00	ខ្សែនឈើ ម្សៅឈើ	**Wood wool; wood flour.**	kg	7	0	10	10	
44.06		ឈើកំណល់ផ្លូវរថភ្លើង និងឈើប្រហាក់ប្រហែល	**Railway or tramway sleepers (cross -ties) of wood.**						
	4406.10.00	- មិនមែនត្រាំដោយវត្ថុធាតុសំរាប់ការពារកុំអោយពុកផុយ	- Not impregnated	m^3	7	0	10	10	
	4406.90.00	- ផ្សេងទៀត	- Other	m^3	7	0	10	10	
44.07		ឈើអារ ឈើចាំងតាមបណ្តោយ ឈើចំណិត ឬបកសំបករួចហើយ ទោះជាឈូសខាត់ ឬតភ្ជាប់ ដែលមានកំរាស់លើសពី ៦ ម.ម ។	**Wood sawn or chipped lengthwise, sliced or peeled, whether or not planed, sanded or finger-jointed, of a thickness exceeding 6 mm.**						
	4407.10.00	- នៃកូនីហ្វែរ	- Coniferous	m^3	7	0	10	10	
		- នៃឈើត្រូពិកដូចមានចែងក្នុងកំណត់សំគាល់ទី៣ំងរងលេខ ១ នៃជំពូកនេះ :	- Of tropical wood specified in Subheading Note 1 to this Chapter:						

	4407.21.00	- - មាហូហ្គានី (Swietenia spp)	- - Mahogany (Swietenia)	m³	7	0	10	10	
	4407.22.00	- - វីរ៉ូឡា អ៊ីមប៊ូ និងបាល់សា	- - Virola, Imbuia and Balsa	m³	7	0	10	10	
	4407.25	- - ឈើ Dark Red Meranti Light Red Meranti and Meranti Bakau	- - Dark Red Meranti, Light Red Meranti and Meranti Bakau:						
	4407.25.10	- - - ឈើ Dark Red Meranti, Light Red Maranti:	- - - Dark Red Meranti, Light Red Maranti:	m³	7	0	10	10	
	4407.25.20	- - - ឈើ Meranti Bakau	- - - Meranti Bakau	m³	7	0	10	10	
	4407.26.00	- - ឈើ White lauan White Meranti White Seraya Yellow Meranti and Alan	- - White Lauan, White Meranti, White Seraya, Yellow Meranti and Alan:	m³	7	0	10	10	
	4407.27.00	- - ឈើ Sapelli	- - Sapelli	m³	7	0	10	10	
	4407.28.00	- - ឈើ Iroko	- - Iroko	m³	7	0	10	10	
	4407.29	- - ផ្សេងទៀត :	- - Other:						
		- - - ឈើ Jelatong	- - - Jelatong						
	4407.29.11	- - - - ឈូស	- - - - Planed	m³	7	0	10	10	
	4407.29.19	- - - - ផ្សេងទៀត	- - - - Other	m³	7	0	10	10	
		- - - ឈើ Kapur	- - - Kapur						
	4407.29.21	- - - - ឈូស	- - - - Planed	m³	7	0	10	10	
	4407.29.29	- - - - ផ្សេងទៀត	- - - - Other	m³	7	0	10	10	
		- - - ឈើ Kempas	- - - Kempas						
	4407.29.31	- - - - ឈូស	- - - - Planed	m³	7	0	10	10	
	4407.29.39	- - - - ផ្សេងទៀត	- - - - Other	m³	7	0	10	10	
		- - - ឈើ Keruing	- - - Keruing						
	4407.29.41	- - - - ឈូស	- - - - Planed	m³	7	0	10	10	
	4407.29.49	- - - - ផ្សេងទៀត	- - - - Other	m³	7	0	10	10	

		- - - ឈើ Ramin	--- Ramin						
	4407.29.51	- - - - ឈូស	---- Planed	m^3	7	0	10	10	
	4407.29.59	- - - - ផ្សេងទៀត	---- Other	m^3	7	0	10	10	
		- - - ឈើមៃសាក់	--- Teak						
	4407.29.61	- - - - កិដានមៃសាក់, ឈូស	---- Teak decks, planed	m^3	7	0	10	10	
	4407.29.69	- - - - ផ្សេងទៀត	---- Other	m^3	7	0	10	10	
	4407.29.70	- - - ឈើ Balau	--- Balau	m^3	7	0	10	10	
	4407.29.80	- - - ឈើ Mengkulang	--- Mengkulang	m^3	7	0	10	10	
		- - - ផ្សេងទៀត :	--- Other :						
	4407.29.91	- - - - ឈើ Jonkong and Merbau (Intsia spp) planed, sanded or end-jointed	---- Jongkong and Merbau (Intsia spp.) planed, sanded or end-jointed	m^3	7	0	10	10	
	4407.29.92	- - - - ឈើ Jongkong and merbau (Intsia spp) ផ្សេងទៀត	---- Jongkong and Merbau (Intsia spp.) other	m^3	7	0	10	10	
	4407.29.99	- - - - ផ្សេងទៀត	---- Other	m^3	7	0	10	10	
		- ផ្សេងទៀត:	- Other:						
	4407.91.00	- - ឈើសែន (Quercus Spp)	-- Of oak (Quercus spp.)	m^3	7	0	10	10	
	4407.92.00	- - ឈើផែត្រ (Fagus Spp)	-- Of beech (Fagus spp.)	m^3	7	0	10	10	
	4407.93.00	- - ឈើមាប	-- Of maple (Acer spp.)	m^3	7	0	10	10	
	4407.94.00	- - ឈើឆើរី	-- Of cherry (Prunus)	m^3	7	0	10	10	
	4407.95.00	- - ឈើអេស	-- Of ash (Fraxinis spp)	m^3	7	0	10	10	
	4407.99.00	- - ផ្សេងទៀត :	-- Other :	m^3	7	0	10	10	

44.08		សន្លឹក វ៉ឺនៀរ និងសន្លឹកសំរាប់ក្តារបន្ទះ (ទោះជាតភ្ជាប់ ឬមិនតភ្ជាប់) និងឈើអារតាមបណ្តោយ ចិត ឬបកសំបក ទោះជាឈូស ខាត់ ឬមិនផាប់ភ្ជាប់ក៏ដោយដែលមានកំរាស់មិនលើសពី ៦ ម.ម ។	**Veneer sheets and sheets for plywood (whether or not spliced) and other wood sawn lengthwise, sliced or peeled, whether or not planed, sanded or finger-jointed, of a thickness not exceeding 6 mm.**						
	4408.10.	- នៃពួកឈើស្រល់ :	- Coniferous :						
	4408.10.10	- - បន្ទះឈើ Cedar សំរាប់រោងចក្រផលិតខ្មៅដៃ	- - Cedar wood slats prepared for pencil manufacture	kg	7	0	10	10	
	4408.10.30	- - បន្ទះក្តារកុំប្លាកេ	- - Face veneer sheets	kg	7	0	10	10	
	4408.10.90	- - ផ្សេងទៀត	- - Other	kg	7	0	10	10	
		- នៃឈើត្រូពិកដូចមានចែងក្នុងកំណត់សំគាល់ទីតាំងលេខ ១ នៃជំពូកនេះ :	- Of tropical woods specified in subheading note 1 to this chapter :						
	4408.31.00	- - ឈើ Dark Red Meranti, Light Red Meranti and Meranti Bakau	- - Dark Red Meranti, Light Red Meranti and Meranti Bakau	kg	7	0	10	10	
	4408.39	- - ផ្សេងទៀត	- - Other						
	4408.39.10	- - - បន្ទះឈើ ជេឡូតុងរៀបចំសម្រាប់ផលិតកម្មខ្មៅដៃ	- - - Jelutong wood slats prepared for pencil manufacture	kg	7	0	10	10	
	4408.39.90	- - - ផ្សេងទៀត	- - - Other	kg	7	0	10	10	
	4408.90.00	- ផ្សេងទៀត :	- Other :	kg	7	0	10	10	

44.09		ឈើ (រាប់បញ្ចូលទាំងបន្ទះតូចៗនិងសំភប់ក្រាលមិនទាន់ផ្គុំ) ថ្ម (លកឈ្មោល លកបង្ករ លកញ្ជី លកដូចមេទ្វារ បង្គួច ភ្ជាប់ជាអក្សរ V លកក្បាច់ ក្រឡឹងអោយមូល ឬប្រហាក់ប្រហែល) តាមបណ្តោយមុខមួយឬមុខច្រើន ទោះជាឈូស ខាត់ ឬតភ្ជាប់ក៏ដោយ ។	Wood (including strips and friezes for parquet flooring, not assembled) continuously shaped (tongued, grooved, rebated, chamfered, V-jointed, beaded, moulded, rounded or the like) along any of its edges or faces, whether or not planed, sanded or finger-jointed.						
	4409.10.00	- នៃកូនីហ្វែរ	- Coniferous	kg	15	0	10	5	
		- មិនមែនកូនីហ្វែរ :	- Non-coniferous :						
	4409.21.00	- - ពីឫស្សី	- - Of bamboo	kg	15	0	10	5	
	4409.29.00	- - ផ្សេងទៀត	- - Other	kg	15	0	10	5	
44.10		ក្តារបន្ទះធ្វើពីកំទេច និងក្តារបន្ទះប្រហាក់ប្រហែលធ្វើពីឈើ ឬធាតុឈើផ្សេងទៀតទោះផ្គុំ ឬមិនទាន់ផ្គុំដោយជ័រ ឬធាតុតភ្ជាប់សរីរាង្គផ្សេងទៀត។	Particle board and similar board of wood or other ligneous materials, whether or not agglomerated with resins or other organic binding substances.						
		- ពីឈើ	- Of wood:						
	4410.11.00	- - បំណែកក្តារតូចៗ	- - Particle board	kg	15	0	10	0	
	4410.12.00	- - ក្តារធ្វើពីកំទេចឈើកបស្នើ ឬមានផ្ទុង	- - Oriented strand board and waferboard, of wood:	kg	15	0	10	0	
	4410.19.00	- - ផ្សេងទៀត	- - Other	kg	15	0	10	0	
	4410.90.00	- ផ្សេងទៀត	- Other	kg	15	0	10	0	
44.11		ក្តារធ្វើពីសរសៃឈើ ឬធាតុឈើផ្សេងទៀត ទោះផ្គុំដោយជ័រ ឬធាតុតភ្ជាប់សរីរាង្គផ្សេងទៀត។	Fibreboard of wood or other ligneous materials, whether or not bonded with resins or other organic substances.						
		- ក្តារដែលមានដង់ស៊ីតេមធ្យម :	- Medium density fibreboard (MDF) :						

តទៅរាជកិច្ចលេខ ៦១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៦៧៥....សហវ..ប្រក-ពណ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០០៧

ប្រកាសអន្តរក្រសួង
ស្តីពី
កម្រៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្ម

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តី

អំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់វិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ

- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥១៤ សហវ.ថហ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការកំណត់អាករលើបែបបទសុំចុះឈ្មោះ លុបឈ្មោះ ឬ ចេញវិញ្ញាបនបត្រផ្សេងៗ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តតាមសារាចរណែនាំ លេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរដ្ឋទេយ្យចំណូល
- អនុវត្តតាមសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៤ ស្តីពីការកែលំអនីតិវិធីអនុវត្តថវិកា
- យោងតាមការចាំបាច់ក្នុងទិសដៅកែទម្រង់ ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម

សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យយកកម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីពាណិជ្ជកម្ម ។

ប្រការ ២ : កម្រៃរដ្ឋបាលក្នុងការចុះឈ្មោះក្រុមហ៊ុន លុបឈ្មោះក្រុមហ៊ុន និង ចេញវិញ្ញាបនបត្រផ្សេងៗ ក្នុងបញ្ជីពាណិជ្ជកម្ម ត្រូវបានកំណត់ដូចខាងក្រោម :

បរិយាយ	**កម្រៃសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម**	**កម្រៃសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម**	**កម្រៃសុំវិញ្ញាបនបត្រផ្សេងៗ**
១. ក្រុមហ៊ុនពាណិជ្ជកម្ម	**៤២០.០០០ រៀល**	**២០០.០០០ រៀល**	**៦០.០០០ រៀល**
ក្នុងនោះ :			
- ការសុំចុះឈ្មោះ	២៦០.០០០ រៀល		
- ទម្រង់បែបបទសុំចុះបញ្ជីពាណិជ្ជកម្ម	១២០.០០០ រៀល		
- ឆែកឈ្មោះ	២០.០០០ រៀល		
- ផ្តល់អត្តលេខ	២០.០០០ រៀល		
២. សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលជាប់ពន្ធលើប្រាក់ចំណេញ	**១២០.០០០ រៀល**	**៦០.០០០ រៀល**	**២០.០០០ រៀល**

ប្រការ ៣ : ការបង់ប្រាក់ និង ការទទួលប្រាក់ចំណូលពីកម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីពាណិជ្ជកម្ម ត្រូវអនុវត្តតាមរយៈរដ្ឋទេយ្យករចំណូលនៅក្រសួងពាណិជ្ជកម្ម ។

ប្រការ ៤ : **ក**-ការគ្រប់គ្រងចំណូលពីកម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីពាណិជ្ជកម្ម ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ និងត្រូវបានកត់ត្រា ក្នុងជំពូក ៧៣ គណនី ៧៣២ អនុគណនី ៧៣២៣ ដោយត្រូវបង់ ១០០% ចូលថវិការដ្ឋ ។

ខ-ក្រសួងពាណិជ្ជកម្មត្រូវបូកសរុបធ្វើរបាយការណ៍ចំណូលប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ) ឱ្យបានទៀងទាត់ ។

ប្រការ ៥ : ការផ្តល់ប្រាក់ឧបត្ថម្ភ ដល់ការគ្រប់គ្រងលើការប្រមូលចំណូលនេះ នឹងត្រូវរៀបចំប្រកាសអន្តរក្រសួងមួយដោយឡែក តាមគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល ។

ប្រការ ៦ : ប្រកាសលេខ ៥១៤ សហវ.ថហ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការកំណត់អាករលើបែបបទសុំចុះឈ្មោះ លុបឈ្មោះ ឬ ចេញវិញ្ញាបនបត្រផ្សេងៗ របស់ក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រកាសលេខ ១៦២ MOC/M 2004 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការកំណត់សោហ៊ុយចំណាយលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧ : គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៨ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
គាត់ ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ចម ប្រសិទ្ធ

<u>ចម្លងជូន :</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់ខេត្ត-ក្រុង
- ដូចប្រការ ៧ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០២ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៧

សារាចរណែនាំ

អនុវត្តន៍ប្រកាសស្តីពី
ការផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈ និង អាជ្ញាប័ណ្ណ
ផ្នែកសេវាកម្មវាយតំលៃ និង សេវាកម្មអចលនវត្ថុ

សារាចរណែនាំនេះត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃលិខិតបទដ្ឋានដូចតទៅ ÷

- ព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៥ លើលិខិតលេខ ៤១៥៧ សហវ. ចុះថ្ងៃ ទី ១១ ខែ កក្កដា ឆ្នាំ ២០០៥
- ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- ប្រកាសលេខ ១៤២ សហវ.ប្រក.ឧហ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណផ្នែកសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ក្នុងគោលបំណងឈានទៅរកការគ្រប់គ្រងសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុដែលកំពុងតែធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរេចចេញសារាចរណែនាំអនុវត្តន៍ប្រកាស លេខ ១៤២ សហវ.ប្រក.ឧហ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណផ្នែកសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ ដែលមានខ្លឹមសារដូចតទៅ÷

១. និយមន័យ

ក. សេវាកម្មអចលនវត្ថុ ដែលមានចែងក្នុងប្រការ ២ នៃប្រកាសលេខ ១៤២ សហវ. ប្រក.ឧហ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណសំដៅដល់÷

- អាជីវកម្ម ដែលធ្វើឡើងដោយក្រុមហ៊ុន លើការទិញ លក់ សាងសង់សំរាប់លក់ ជួល បញ្ចាំ ដីធ្លី ផ្ទះសំបែង ដែលជាទ្រព្យសម្បត្តិផ្ទាល់របស់ក្រុមហ៊ុន ។

- អាជីវកម្ម ដែលធ្វើឡើងដោយក្រុមហ៊ុន លើការទិញ លក់ ជួល បញ្ចាំ ដីធ្លី ផ្ទះសំបែង ដែលឈរលើមូលដ្ឋានកិច្ចសន្យា ឬកំរៃ ។ ក្នុងន័យនេះ អាជីវកម្ម សំដៅដល់ សេវាកម្មដែលក្រុមហ៊ុនធ្វើឡើងដើម្បីទទួលបានកំរៃជើងសារក្នុងការទិញ លក់ ជួល បញ្ចាំ ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អតិថិជនដែលជារូបវន្តបុគ្គល ឬនីតិបុគ្គល ។

ខ. សេវាកម្មវាយតំលៃអចលនវត្ថុ សំដៅដល់ ការវាយតំលៃអចលនវត្ថុដែលធ្វើឡើងត្រឹមត្រូវតាមជំនាញ និងក្រមវិជ្ជាជីវៈ ដោយមានការទទួលខុសត្រូវលើតំលៃអចលនវត្ថុស្របតាមតំលៃទីផ្សារ ។ ការវាយតំលៃអចលវត្ថុត្រូវធ្វើឡើងដោយភាពឯករាជ្យ មិនមានការក្លែងបន្លំ មិនមានភាពលំអៀង និងមិនធ្វើអោយមានការយល់ខុសលើតំលៃអចលនវត្ថុ ដែលបានវាយតំលៃ ។

២. ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនដោយគ្មានអាជ្ញាប័ណ្ណ

យោងតាមប្រការ ១៤ នៃប្រកាសលេខ ១៤២ សហវ.ប្រក.ឧហ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណផ្នែកសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ ក្រុមហ៊ុនណាដែលផ្តល់សេវាកម្មវាយតំលៃ ឬសេវាកម្មអចលនវត្ថុ ដូចអត្ថន័យបញ្ជាក់ខាងលើដោយគ្មានអាជ្ញាប័ណ្ណពីក្រសួង ត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចំនួន ១០ លានរៀល (ដប់លានរៀល) ។ ក្នុងករណីនៅតែបន្តធ្វើអាជីវកម្មដោយពុំព្រមមកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុទេនោះ ក្រុមហ៊ុនត្រូវទទួលការផាកពិន័យទ្វេដងគឺ ២០ លានរៀល (ម្ភៃលានរៀល) និងត្រូវបិទអាជីវកម្មជាបន្ទាន់ ហើយត្រូវមកបំពេញបែបបទស្នើសុំអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ករណីមិនអនុវត្តតាមនេះ ក្រសួងនឹងចាត់វិធានការតឹងរឹងទៅតាមផ្លូវច្បាប់ជាធរមាន ។

ចំពោះប្រាក់ផាកពិន័យ គឺត្រូវបង់ដោយផ្ទាល់ទៅរតនាគារជាតិ តាមដីកាអមរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៣. សុពលភាពនៃសារាចរ

សារាចរនេះមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទទួលបានសារាចរណែនាំនេះ អគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានពន្ធដារ និងនាយកដ្ឋានពាក់ព័ន្ធដទៃទៀត ក្រោមឱវាទ និងក្រុមហ៊ុនវាយតំលៃ ក្រុមហ៊ុនអចលនវត្ថុដែលកំពុងធ្វើសេវាកម្មវាយតំលៃ ឬសេវាកម្មអចលនវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តតាមប្រកាសលេខ ១៤២ សហវ.ប្រក. ឧបាចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណ ផ្នែកសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ និងសារាចរណែនាំនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ដូចក្នុងចំណុច ៣ ដើម្បីសហការអនុវត្ត
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ៣៣៤.......... ប្រក.កសក

ប្រកាស

ស្តីពី

ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនៃផលិតផលកសិកម្ម

*****

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសម្របសម្រួលការត្រួតពិនិត្យគុណភាព សុវត្ថិភាពផលិតផល និងសេវាកម្ម
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ២០០១ កែសម្រួល និងបំពេញបន្ថែមអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សម្របសម្រួលការត្រួតពិនិត្យគុណភាព សុវត្ថិភាព ផលិតផលកសិកម្ម និងសេវាកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីអនាម័យនៃម្ហូបអាហារសម្រាប់មនុស្ស

